A Royal Women's Hospital
**Well Women's Publication**

Women's Health Matters



# គ្រឿងផ្សំពីរុក្ខជាតិ នៅក្នុងពេលមានផ្ទៃពោះ

ប្រទេសជាច្រើនបានប្រើគ្រឿងថ្នាំផ្សំពីរុក្ខជាតិអស់ពេលជាច្រើនសតវត្សរ៍មកហើយ ដើម្បីព្យាបាលជម្ងឺផ្សេងៗមួយចំនួនធំ។ Naturopaths (គ្រូពេទ្យព្យាបាលដោយវិធីធម្មជាតិ), homoeopaths (គ្រូពេទ្យព្យាបាលដោយប្រើមេរោគបង្កើតឲ្យមានជម្ងឺ), herbalists (អ្នកស្គាល់គ្រឿងផ្សំពីរុក្ខជាតិ) និងគ្រូពេទ្យថែទាំសុខភាពឯទៀត កំពុងស្នើឲ្យប្រើ ឬឲ្យប្រើថ្នាំផ្សំពីរុក្ខជាតិកាន់តែញឹកញាប់ឡើងនៅក្នុងប្រទេសអូស្ត្រាលី។

ប័ណ្ណពត៌មាននេះ មានគោលបំណងធ្វើជាគោលការណ៍ណែនាំមួយតែប៉ុណ្ណោះ ហើយពត៌មាននេះ ត្រូវបានផ្អែកទៅលើតិរិះវិជ្ជាគ្រាសព្វថ្ងៃអំពីថ្នាំផ្សំពីរុក្ខជាតិ និងផលប៉ះពាល់របស់ថ្នាំទាំងនេះ។

នៅគ្រប់ករណីទាំងអស់ អ្នកជម្ងឺគួរតែស្វែងរកឱវាទ បើគិតគូរលើការប្រើថ្នាំផ្សំពីរុក្ខជាតិណាមួយ ក្នុងអម្លុងពេលមានផ្ទៃពោះ ឬ ពេលឲ្យកូនបៅដោះ។

Drug Information Centre (មជ្ឈមណ្ឌលពត៌មានឱសថ)នៃ Royal Women's Hospital មិនស្នើសុំឲ្យប្រើគ្រឿងផ្សំពីរុក្ខជាតិក្នុងអម្លុងពេលមានផ្ទៃពោះ ឬពេលបំបៅកូនដោយទឹកដោះម្តាយទេ ដោយសារតែមានការខ្វះខាតឯកសារពត៌មានអំពីសុវត្ថិភាពនៃការប្រើវា។ បើមានគេស្នើសូមឲ្យអ្នកប្រើគ្រឿងផ្សំពីរុក្ខជាតិ ហើយអ្នកមានផ្ទៃពោះឬបំបៅដោះឲ្យកូន វាជាការសំខាន់ណាស់ក្នុងការសាកសួរអ្នកដែលចេញបញ្ជាឲ្យអ្នកប្រើ អំពីសុវត្ថិភាពនៃគ្រឿងផ្សំនេះ ចំពោះអ្នកនិងទារកអ្នក។

នៅពេលមានលទ្ធភាព អ្នកគួរតែចៀសវាងគ្រឿងផ្សំពីរុក្ខជាតិក្នុងអម្លុងរយៈពេលបីខែដំបូងនៃការមានផ្ទៃពោះ។ យ៉ាងណាមិញ អ្នកប្រហែលជាអាចប្រើផលិតផលផ្សំពីរុក្ខជាតិខ្លះ ក្រោយពីពេលបីខែដំបូង។ សូមពិភាក្សាជាមួយអ្នកចេញបញ្ជាឲ្យប្រើដើម្បីទទួលពត៌មានបន្ថែម។

## មូលហេតុដែលត្រូវប្រុងប្រយ័ត្ន

- ភាគច្រើននៃថ្នាំផ្សំពីរុក្ខជាតិនិងថ្នាំផ្សំដោយមេរោគសំរាប់បង្កើតឲ្យមានជម្ងឺ មិនទាន់បានធ្វើតេស្តដើម្បីកំណត់សុវត្ថិភាពរបស់វា ក្នុងអម្លុងពេលមានផ្ទៃពោះនិងពេលបំបៅកូនដោយទឹកដោះម្តាយនៅឡើយទេ។
- ជាញឹកញយ ថ្នាំផ្សំពីរុក្ខជាតិមានតម្លៃថ្លៃគួរសមដែរ ហើយថ្នាំជាច្រើន មិនទាន់មានភស្តុតាងខាងផ្នែកវិទ្យាសាស្ត្រ ថាមានប្រសិទ្ធភាពឡើយ។
- គ្មានថ្នាំណាមួយគឺជាគ្រឿងជំនួសឲ្យចំណីអាហារល្អប្រសើរ ការហាត់ប្រាណគ្រប់គ្រាន់ និងដំណេកពេញលេញនោះទេ។
- គ្មានភស្តុតាងថា ថ្នាំផ្សំពីរុក្ខជាតិជាគ្រឿងមានសុវត្ថិភាពនិងប្រសិទ្ធភាពជំនួសឲ្យថ្នាំពេទ្យដែលចេញបញ្ជាឲ្យប្រើដោយវេជ្ជបណ្ឌិតឡើយ។



THE ROYAL WOMEN'S HOSPITAL

ប័ណ្ណពត៌មានអំពីការមានផ្ទៃពោះនិងការសំរាលកូន : ខែឧសភា ឆ្នាំ 2002
គ្រឿងផ្សំពីរុក្ខជាតិនៅក្នុងពេលមានផ្ទៃពោះ (តពីទំព័រមុន)

# ពេលវេលានិងអ្វីៗដែលត្រូវចៀសវាង

ក្នុងអម្លុងពេល 12 អាទិត្យដំបូង និងពេល 12 អាទិត្យចុងក្រោយនៃពេលមានផ្ទៃពោះ សូមចៀសវាងគ្រឿងផ្សំពីរុក្ខជាតិទាំងអស់:

- បើមានប្រវត្តិនៃការរលូតកូនពិតប្រាកដ ឬ មានគ្រោះថ្នាក់ជិតរលូតកូន។
- បើមានប្រវត្តិនៃការលំបាកក្នុងការចាប់ផ្តើមមានផ្ទៃពោះ។
- បើមានការឈឺពោះ។
- បើមានការឈឺចង្កេះ។

**អ្នកក៏គប្បីចៀសវាងផងដែរ នូវ**

- គ្រឿងផ្សំពីរុក្ខជាតិសំរាប់ធ្វើឲ្យរាក។
- គ្រឿងផ្សំពីរុក្ខជាតិដែលមានផលប៉ះពាល់ធ្វើឲ្យកម្រើកដល់ស្បូន។
- គ្រឿងផ្សំពីរុក្ខជាតិដែលជួយធ្វើឲ្យមានរដូវ។

បញ្ជីរាយឈ្មោះគ្រឿងផ្សំពីរុក្ខជាតិដែលអ្នកគួរចៀសវាង មានច្រើនគួរសមដែរ។ ឈ្មោះ គ្រឿងផ្សំពីរុក្ខជាតិនៅខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះតែប៉ុណ្ណោះ :

| | | |
|---|---|---|
| Pennyroyal | Mugwort | Bryonia |
| Angelica | Sage (តាមបរិមាណច្រើន) | Golden Seal |
| Senna | Origanum Oil | Male fern |
| Feverfew | Mistletoe | Parsley in medicinal dosage |
| Liquorice (នៅក្នុងករណីខ្លះ) | Kelp | Rue |
| Kombucha tea | Juniper | Southerwood |
| Dong Quai | Aloes | Autumn crocus |
| Gingko Biloba | Blue or black cohosh | Wormwood |
| Nutmeg (តាមកំរិតខ្ពស់) | Irish Moss | Buckthorn |
| Echinacea | Tansy | Roe |
| Broom | Thuja | Peppermint (តាមកំរិតខ្ពស់) |
| Mandrake | Barberry | Blackroot |

**វីតាមីននិងខនិជដែលត្រូវចៀសវាង**

វីតាមីន A (Retinol)

វីតាមីន C (តាមកំរិតមិនលើសពី 1000 មីលីក្រាម ជាប្រចាំថ្ងៃ)

**មុនពេលប្រើគ្រឿងផ្សំពីរុក្ខជាតិនៅក្នុងពេលមានផ្ទៃពោះ ចូរទាក់ទង naturopath** (គ្រូពេទ្យព្យាបាលដោយវិធីធម្មជាតិ), **homoeopath** (គ្រូពេទ្យព្យាបាលដោយប្រើមេរោគបង្កើតឲ្យមានជម្ងឺ), **ឬ herbalist** (អ្នកស្គាល់គ្រឿងផ្សំពីរុក្ខជាតិ) **របស់អ្នក។**

**The Royal Women's Hospital Drug Information Centre**
**ពេលម៉ោង:** 9 ព្រឹក – 5 ល្ងាច ថ្ងៃច័ន្ទ – ថ្ងៃសុក្រ **ទូរស័ព្ទ:** (03) 9344 2277
**Email:** rwhdrug@cryptic.rch.unimelb.edu.au
**ក្រោយពេលម៉ោងធ្វើការ:** ម៉ាស៊ីនថតទុកបណ្តាំ **ទូរសារ:** (03) 9349 2756